ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលតួនាទី ភារកិច្ចរបស់ នាយកដ្ឋានពត៌មានទូទៅ នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ ..**

ត្រូវបានធ្វើការកែសំរួល តួនាទី ភារកិច្ច របស់នាយកដ្ឋានពត៌មានទូទៅ នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ ។ ការកែសំរួលនេះ ក្នុងគោលបំណងដើម្បីលើកកំពស់ប្រសិទ្ធភាពការងារបំរើអោយវិស័យសន្តិសុខជាតិ សន្តិសុខសង្គម និងដើម្បីអោយសមស្របទៅនឹងសភាពការណ៍របស់ប្រទេសជាតិនាដំណាក់កាលបច្ចុប្បន្ន ។

**មាត្រា២ ..**

នាយកដ្ឋានពត៌មានទូទៅ មានតួនាទីធ្វើសេនាធិការជូនថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ លើការងារស្រាវជ្រាវ ប្រមូលពត៌មានចំហរនិងសំងាត់ ដែលពាក់ព័ន្ធដល់វិស័យសន្តិសុខជាតិ សំដៅរកអោយឃើញនូវសកម្មភាពអមិត្ត សកម្មភាពវិទ្ធង្សនាសង្គម សកម្មភាពល្មើសច្បាប់របស់រដ្ឋ អំពើភេរវកម្ម បទល្មើសឆ្លងដែន បទល្មើសជួញដូរផ្លូវភេទ ហិរញ្ញវត្ថុ និងសកម្មភាពមិនប្រក្រតីនានា ដើម្បីស្នើយោបល់ជូនថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃមានវិធានការ ។

មាត្រា៣ .-

នាយកដ្ឋានពត៌មានទូទៅមានភារកិច្ច ដូចខាងក្រោម :

- ស្រាវជ្រាវប្រមូលពត៌មានជាតិ អន្តរជាតិ ដើម្បីបំរើដល់ការងារសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា ។
- ស្រាវជ្រាវប្រមូលពត៌មាន និងតាមដានការងារសន្តិសុខ និងការសំងាត់ជាតិតាមបណ្តាស្ថាប័ន ក្រសួង មន្ទីរ និងគ្រឹះស្ថានសាធារណៈរបស់រដ្ឋ ។
- ស្រាវជ្រាវ ស៊ើបបញ្ជាក់ពត៌មាន តាមមធ្យោបាយឧបករណ៍បច្ចេកទេសនិងកំលាំងស៊ើបការ ដើម្បីប្រមូលភស្តុតាង បំរើកិច្ចប្រតិបត្តិការជំនាញនិងការអនុវត្តច្បាប់ ។
- ត្រួតពិនិត្យបច្ចេកទេស បង្រ្កាបបទល្មើស និងហាមពលរដ្ឋខ្មែរចូលបនល្បែង ក្លឹបកំសាន្ត ក្លឹបផ្សងសំណាងស្របច្បាប់គ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ពន្ធ ដើម្បី :
  - ពិនិត្យតាមដានសកម្មភាពលើវិស័យអប់រំវប្បធម៌ សិល្បៈ ប្រពន្ធ័ឃោសនា សេវាកម្ម ផលិតកម្មផ្សព្វផ្សាយចែកចាយពត៌មាន
  - ស្រាវជ្រាវប្រមូលពត៌មានតាមបណ្តាក្រុមហ៊ុន សហគ្រាស គ្រឹះស្ថានឯកជន និងបណ្តាអង្គការសហគមមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា
  - ត្រួតពិនិត្យការប្រើប្រាសប្រពន្ធ័ប្រៃសណីយ៍និងប្រពន្ធ័ទូរគមនាគមន៍ គ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ចូលរួមសហការស្រាវជ្រាវបង្រ្កាប និងដោះស្រាយនូវរាល់ករណីចាំបាច់ ដែលមានវិសាលភាពពាក់ពន្ធ័គ្រប់វិស័យដល់បណ្តាស្ថាបន័ ក្រសួងមន្ទីរ សហគម សាសនា និងខេត្ត ក្រុង តាមបញ្ជាថ្នាក់លើ
- ទំនាក់ទំនងជាមួយបណ្តាស្ថានប័ន ក្រសួងមន្ទីរ គ្រឹះស្ថាន សហគ្រាស អង្គការ សហគម និងអង្គភាពពាក់ពន្ធ័ ផ្តល់នូវឯកសារ តួលេខ និងពត៌មានផ្សេងៗតាមតំរូវការនៃវិធានការស្រាវជ្រាវរបស់ជំនាញនៃករណីនីមួយៗ ដែលថ្នាក់លើ គល់រោយ ដើម្បីបូកសរុបរាយការណ៍ជូនថ្នាក់លើពិនិត្យសំរេច
- សហការជាមួយបណ្តាស្ថាប័នរដ្ឋ ឯកជន ដើម្បីកសាងបទដ្ឋាននិងលើកវិធានការការពារសន្តិសុខ សុវត្ថិភាពជូនឥស្សរជនសំខាន់ៗនិងតាមគោលដៅនីមួយៗ
- ប្រមូលពត៌មាន ស្ថាបស្ទង់មតិក្នុងសង្គមលើព្រឹត្តិការណ៍សំខាន់ៗ ដើម្បីបូកសរុប វាយតំលៃ សន្និដ្ឋានជូនថ្នាក់ដឹកនាំពិចារណា
- ទំនាក់ទំនងនិងសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានា តាមគោលការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ដើម្បីផ្លាស់ប្តូរពត៌មានជាមួយស្ថាប័នជំនាញ
- បូកសរុប វិភាគពត៌មាន ផ្តើមសុំគោលការណ៍លើវិធានការណ៍ជំនាញ ដើម្បីរាយការណ៍ជូនថ្នាក់លើពិនិត្យ សំរេច
- តាមដាន ត្រួតពិនិត្យ ណែនាំ ដល់នគរបាលខេត្ត ក្រុងអំពីវិធានការណ៍ជំនាញដែលពាក់ពន្ធ័ដល់កិច្ចប្រតិបត្តិការ ស្រាវជ្រាវប្រមូលពត៌មាន
- រៀបចំផែនការ កសាងសមត្ថភាពធនធានមនុស្ស ទាំងជំនាញភាសារបរទេស និងបច្ចេកទេសវិទ្យាសាស្ត្រទំនើប

- ប្រជុំដកពិសោធន៍ កែលំអរកិច្ចប្រតិបត្តិការ លើកកំពស់ប្រសិទ្ធិភាពការងារដឹកនាំ និងពង្រឹងការអនុវត្តបទបញ្ជារបស់ថ្នាក់លើ
- ធ្វើការបូកសរុប គ្រប់គ្រងឯកសារ ការងារបុគ្គលិក គណនេយ្យ ភស្តុភាររបស់នាយកដ្ឋាន តាមការកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់អោយ ។

**មាត្រា៤ ._**

នាយកដ្ឋានពន្ធនាគារទូទៅ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយ ។

**មាត្រា៥ ._**

នាយកដ្ឋានពន្ធនាគារទូទៅមានការិយាល័យមួយចំនួនចំណុះ ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានពន្ធនាគារទូទៅ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៦ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៧ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ពន្ធ័ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- ឯកសារ-កាលប្បវត្តិ